# ឯកសារឧស្សនទាន សម្រាប់សិក្ខាសាលាថ្នាក់ក្រោមជាតិស្តីពី

## ប្រព័ន្ធទំនាក់ទំនងសង្គម និង ឧបករណ៍មិនបង្កទំនាស់

### ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅសណ្ឋាគារ ប្រេស៊ីដង់ ទីរួមខេត្តបាត់ដំបង

## សេចក្តីផ្តើម

ដើម្បីប្រសិទ្ធភាពការងារក្នុងកម្មវិធី និងស្ថាប័ន ក្នុងយុគសម័យឌីជីថល ការប្រាស្រ័យទាក់ទងតាមប្រព័ន្ធអ៊ីនធឺណេត បានក្លាយជាច្រកដ៏សំខាន់ក្នុងការបញ្ជូនសារ ក៏ដូចជាយុទ្ធសាស្ត្រផ្សេងៗក្នុងការអនុវត្តការងារ។ ដោយឃើញនិន្នាការថ្មីនេះ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) ដោយមានការជួយជ្រោមជ្រែងពីអង្គការដៃគូ និងអង្គការសមាជិកក្នុងខេត្ត នឹងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ប្រព័ន្ធទំនាក់ទំនងសង្គម និងឧបករណ៍មិនបង្កទំនាស់ ក្នុងខេត្តទីរួមបាត់ដំបង នៅថ្ងៃទី <u>១២ ខែវិច្ឆិកា ឆ្នាំ ២០១៨</u>។ សិក្ខាសាលានេះ នឹងចែករំលែក ពិភាក្សាអំពីតម្រូវការរបស់សមាជិក និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ដោយផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធទំនាក់ទំនងសង្គម រួមទាំងប្រសិទ្ធភាពនៃឧបករណ៍ទំនាក់ទំនងសង្គម និងឧបករណ៍មិនបង្កទំនាស់សម្រាប់កម្មវិធី និងស្ថាប័ន។

បច្ចុប្បន្នភាពផ្នែកទំនាក់ទំនង សម្រាប់គោលការណ៍ណែនាំប្រព័ន្ធទំនាក់ទំនងសង្គម (Version 2) ត្រូវបានបោះពុម្ពផ្សាយ និងត្រៀមរួចរាល់សម្រាប់ការផ្សព្វផ្សាយដល់សមាជិក និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាល។ នេះគឺជាវេទិកាមួយ ដែលអាចទទួលបានព័ត៌មានថ្មីៗ ទាក់ទងនឹងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម សម្រាប់បណ្តាអង្គការខេត្តមួយចំនួន នៃខេត្តជាដៃគូចំនួន ១៥ រួមមាន៖ ខេត្តរតនគិរី ក្រចេះ ស្ទឹងត្រែង ព្រៃវែង ស្វាយរៀង កំពង់ធំ សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង មណ្ឌលគិរី និង តាកែវ ជាដើម។

ម្យ៉ាងទៀត ដោយមានការសហការពីអង្គការ Bread for the World (BfdW) ឧបករណ៍មិនបង្កទំនាស់ (DNH) ត្រូវបានយកមកបង្ហាញតាមរយៈសិក្ខាសាលាជាស៊េរី។ ដើម្បីស្គាល់កាន់តែច្បាស់ពីកត្តាបែកបាក់ និងកត្តាផ្សារភ្ជាប់ និងដើម្បីបង្កើនសមត្ថភាពយកចិត្តទុកដាក់នឹងទំនាស់របស់គម្រោងការផ្សព្វផ្សាយពីឧបករណ៍មិនបង្កទំនាស់ ត្រូវបានរៀបចំឡើងដោយក្រុមការងារ និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត។

ដូចនេះហើយ អង្គការ CCC ដែលជាអង្គការសមាជិកភាពឈានមុខគេ ដែលបានបង្កើតឡើងតាំងពីឆ្នាំ ១៩៩០ និងមានអង្គការសមាជិកមិនមែនរដ្ឋាភិបាល ក្នុងស្រុក និងបរទេសជិត ១៨០ នៅទូទាំងប្រទេសកម្ពុជា។ ក្រោមកិច្ចសហការជ្រោមជ្រែងពីតំណាងអង្គការមិនមែនរដ្ឋាភិបាលខេត្តបាត់ដំបង បន្ទាយមានជ័យ ពោធិ៍សាត់ និងកំពង់ឆ្នាំង សិក្ខាសាលានេះឡើង ដែលមានសមាសភាពចូលរួមពីថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងមន្ត្រីកម្មវិធីតំណាង ក៏ដូចមន្ត្រីផ្នែកទំនាក់ទំនង ដែលមានចំនួនសរុបប្រមាណ ៥០-៦០ នាក់។

## គោលបំណងសិក្ខាសាលា

សិក្ខាសាលានេះ មានគោលបំណងដើម្បីៈ

- ធ្វើទស្សនកិច្ច និង លើកកម្ពស់ភាពជាសមាជិកភាពរបស់អង្គការ CCC សម្រាប់អង្គការសមាជិក និងមិនមែនសមាជិក
- ស្វែងយល់ពីការងារអភិវឌ្ឍន៍ និងបញ្ហាប្រឈមផ្សេងៗ នៅថ្នាក់ក្រោមជាតិ
- ចែករំលែកគោលការណ៍ណែនាំស្តីពីប្រព័ន្ធទំនាក់ទំនងសង្គម (Social Media Version 2) និងពិភាក្សាពីតម្រូវការនៃប្រព័ន្ធទំនាក់ទំនងសង្គម ព្រមទាំងពិភាក្សាពីឧបករណ៍មិនបង្កទំនាស់ដែលអាចធ្វើឲ្យការអនុវត្តកម្មវិធីកាន់តែប្រសើរ

## សមាសភាពចូលរួម និងទីកន្លែង

សិក្ខាសាលានេះ នឹងរៀបចំឡើងនៅ**សណ្ឋាគារ ប្រេស៊ីដង់ ក្នុងទីរួមខេត្តបាត់ដំបង** ដោយមានសមាសភាពចូលរួមប្រមាណ ៦០នាក់ ដែលក្នុងនោះតំណាងមកពី ខេត្តបន្ទាយមានជ័យប្រមាណ ១០នាក់ ខេត្តពោធិ៍សាត់ប្រមាណ ១០នាក់ និងខេត្តកំពង់ឆ្នាំងប្រមាណ ១០នាក់ ដែលជាអង្គការសមាជិក និងមិនមែនសមាជិក ក៏ដូចជាអង្គការដៃគូផ្សេងៗ។

## លទ្ធផលរំពឹងទុក

- អង្គការសមាជិក និងដៃគូបណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត នឹងយល់ដឹងអំពីយន្តការសម្រាប់អង្គការសមាជិកភាព និងយល់ដឹងពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការ ក៏ដូចជាប្រសិទ្ធភាពនៃឧបករណ៍ទំនាក់ទំនងសង្គម និងឧបករណ៍មិនបង្កទំនាស់។
- អង្គការសមាជិក និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ខេត្ត អាចរៀបរាប់ពីតម្រូវការរបស់ខ្លួន និងសារៈសំខាន់នៃប្រព័ន្ធទំនាក់ទំនងសង្គមសម្រាប់ក្រុមគោលដៅ និងដៃគូនានា
- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) នឹងយល់អំពីអង្គការសមាជិក និងមិនមែនសមាជិក ព្រមទាំងអាចរៀបចំឧបករណ៍ទំនាក់ទំនង និងយុទ្ធសាស្ត្រផ្សេងទៀតបានកាន់តែប្រសើរ។

## របៀបវារៈសម្រាប់សិក្ខាសាលា

| ពេលវេលា | កម្មវិធី | អ្នកសម្របសម្រួល |
|---|---|---|
| 8:00-8:30 | **ការចុះឈ្មោះអ្នកចូលរួម** | អង្គការ CCC និងបណ្ដាញអង្គការខេត្ត |
| 8:30-8:50 | **មតិស្វាគមន៍ និងការបើកកម្មវិធីសិក្ខាសាលា**<br>- គោរពភ្លេងជាតិ<br>- បង្ហាញពីកម្មវិធី<br><br>- កិច្ចស្វាគមន៍ និងបើកកម្មវិធី | អ្នកកាន់កម្មវិធី<br><br>CCC និង បណ្ដាញអង្គការខេត្ត |
| 8:50-10:00 | **វគ្គទី១៖ ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព**<br>- តើអ្វីជាការទំនាក់ទំនង?<br>- ហេតុអ្វីបានជាវាសំខាន់សម្រាប់ CSO?<br>- ដំណើរការទំនាក់ទំនង<br>**សំនួរ - ចម្លើយ** | - **លោកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង (CCC) |
| 10:00-10:20 | សំរាកអាហារសំរ៉ន់ | |
| 10:20-11:30 | **វគ្គទី២៖ ការផ្សព្វផ្សាយឧបករណ៍ទំនាក់ទំនង**<br>- ប្រព័ន្ធទំនាក់ទំនង និងផ្សព្វផ្សាយសង្គម (Version 2)<br>- ប្រព័ន្ធគ្រប់គ្រងទិន្នន័យអង្គការមិនមែនរដ្ឋាភិបាល<br>- ប្រព័ន្ធអនឡាញរបស់ CCC<br>- ការផ្សព្វផ្សាយសមាជិកភាពរបស់ CCC និងសំណើផ្សេងៗ<br>**សំនួរ - ចម្លើយ** | - **លោកស្រី ស៊ិន ពុទ្ធារី**<br>ប្រធានផ្នែកទំនាក់ទំនង (CCC) |
| 11:30-12:00 | **វគ្គទី៣៖ ការសិក្សាតម្រូវការប្រព័ន្ធទំនាក់ទំនង**<br>- សំណួរស្តីពីប្រព័ន្ធទំនាក់ទំនងក្នុងស្ថាប័ន/កម្មវិធី | - **លោក ឈួក ផលពុទ្ធិរិទ្ធិ**<br>អ្នកឯកទេសទំនាក់ទំនង (CCC) |
| 12:00-13:30 | អាហារថ្ងៃត្រង់រួមគ្នា | ទាំងអស់គ្នា |
| 13:30-14:45 | **វគ្គទី៤៖ ការផ្សព្វផ្សាយ ឧបរណ៍មិនបង្កទំនាស់**<br>- កត្តាបែកបាក់ និង កត្តាផ្សាភ្ជាប់<br>(ករណីសិក្សា) | - **លោកស្រី លុយ ធារី**<br>អ្នកសម្របសម្រួលគម្រោង (CCC) |
| 14:45-15:25 | **វគ្គទី៥៖ កំណត់បញ្ហាប្រឈមនៅថ្នាក់ក្រោមជាតិ**<br>- តើអ្វីជាបញ្ហាប្រឈមរបស់ស្ថាប័នអ្នកក្នុងការការអនុវត្តគម្រោង/កម្មវិធី? | - **លោក រី សុវណ្ណា**<br>អ្នកឯកទេសស្រាវជ្រាវ និងគោលនយោបាយ (CCC) |
| 15:25-15:40 | សំរាកអាហារសំរ៉ន់ | |
| 15:40-16:40 | **វគ្គទី៦៖ ការសិក្សាពីសូចនាករ (GHP)**<br>- ការសិក្សាពីលទ្ធផលគម្រោង | - **លោក រ៉ង សៀន**<br>អ្នកឯកទេសត្រួតពិនិត្យវាយតម្លៃ និងរបាយការណ៍ (CCC) |
| 16:40-17:00 | **វាយតម្លៃវគ្គសិក្ខាសាលា និងមតិបិទកម្មវិធី** | CCC និង បណ្ដាញអង្គការខេត្ត |

**សំគាល់៖** អ្នករៀបចំកម្មវិធីសូមរក្សាសិទ្ធិក្នុងការកែប្រែរបៀបវារៈក្នុងករណីចាំបាច់។